**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១២០៧ សហវ.អសក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៥

**ជម្រាបជូន**

**ឯកឧត្តមអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖ លទ្ធផលសវនកម្មលើទីតាំងដំណើរការ និងស្តារទិន្នន័យ FMIS នៃនាយកដ្ឋានព័ត៌មានវិទ្យា។**

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមអគ្គលេខាធិការជ្រាបថា យោងរបាយការណ៍សវនកម្មរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងលើទីតាំងដំណើរការ និងស្តារទិន្នន័យ FMIS (FMIS Processing Data and Disaster Recovery Sites) ខ្ញុំសូមឯកឧត្តមណែនាំនាយកដ្ឋានព័ត៌មានវិទ្យាឱ្យយកចិត្តទុកដាក់ពង្រឹងបន្ថែមនិងឱ្យបានទាន់ពេលវេលាកំណត់លើបញ្ហាមួយចំនួន ដូចខាងក្រោម៖

- ភាពគ្រប់គ្រាន់នៃធនធានមនុស្ស និងការប្រគល់ភារកិច្ចបានច្បាស់លាស់
- បង្កើតគោលនយោបាយ និងស្តង់ដារសុវត្ថិភាព IT ទូទៅ
- ប្រព័ន្ធត្រួតពិនិត្យបរិស្ថាននិងរូបវន្តដើម្បីសុវត្ថិភាពនៅទីតាំងដំណើរការទិន្នន័យ និងស្តារទិន្នន័យ
- ប្រព័ន្ធត្រួតពិនិត្យតក្ក (Logical Control) (ពាក្យសម្ងាត់ ការបញ្ជូនព័ត៌មានអំពីបញ្ហា)
- ប្រព័ន្ធត្រួតពិនិត្យបណ្តាញ (បញ្ជីសារពើភ័ណ្ឌ សិទ្ធិចូលផ្ទាល់និងពីចំងាយ ខ្សែភ្ជាប់ទីតាំងទាំងពីរ កម្មវិធីអ៊ិនគ្រីប នីតិវិធីកត់ត្រា)
- ឯកសារនិងប្រព័ន្ធត្រួតពិនិត្យផ្នែកទន់ (គោលនយោបាយ នីតិវិធី និងរយៈពេលរក្សាទុក)
- ការចម្លងទុក (Back up) និងការស្តារឡើងវិញ (Recovery) (មន្ត្រី ការបណ្តុះបណ្តាល ការធ្វើតេស្ត គោលនយោបាយនិងនីតិវិធីនៃការចម្លងទុក និងផែនការស្តារឡើងវិញ)
- ការធានានិរន្តរភាពចរន្តអគ្គិសនីនៅតាមរតនាគារខេត្តមួយចំនួន។

ទន្ទឹមនឹងនេះ សូមឯកឧត្តមសហការជាមួយឯកឧត្តមប្រធាន FMWG ដើម្បីធានាឱ្យអនុសាសន៍ពាក់ព័ន្ធនឹងបញ្ហាខាងលើត្រូវបានសម្រេចពេញលេញនិងទាន់ពេល ហើយក្នុងករណីមានតម្រូវការផ្សេងនៅក្រៅកិច្ចសន្យា សូមរាយការណ៍មកខ្ញុំភ្លាមដើម្បីពិនិត្យសម្រេច។ សវនករត្រូវចូលរួមទទួលការបណ្តុះបណ្តាលតាមការចាំបាច់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងមានវិធានការដោយប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**